ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពង់ធំ

លេខ៖ ០៦២/១៨.ស.ណ.ន

# សេចក្តីណែនាំ
## ស្តីពី
## ការរៀបចំបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ
## ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២ គ.ស. ២០១៨

**យោង** ÷ ផែនការណែនាំលេខ ០២/២០១៨ គជបអ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ។

ជារៀងរាល់ឆ្នាំ ប្រជារាស្ត្រខ្មែរយើងទាំងក្នុង និងក្រៅប្រទេស តែងតែប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី ជាប្រពៃណីជាតិរបស់ខ្លួន ក្នុងមនោសញ្ចេតនាសប្បាយរីករាយ ប្រកបដោយស្មារតីសាមគ្គីភាពជិតស្និទ្ធ និង កតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត។

ឆ្នាំនេះ ពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ គ.ស.២០១៨ នឹងប្រព្រឹត្តិទៅតាមដំណើរសង្ក្រាន្តដូចតទៅ៖

- ថ្ងៃសៅរ៍ ១៤រោច ខែចេត្រ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៤ ខែមេសា គ.ស.២០១៨ វេលាម៉ោង ៩.១២នាទីព្រឹក ជាថ្ងៃចូលឆ្នាំ។
- ថ្ងៃអាទិត្យ ១កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៥ ខែមេសា គ.ស.២០១៨ ជាថ្ងៃវ័នបត។
- ថ្ងៃចន្ទ ២កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែមេសា គ.ស.២០១៨ ជាថ្ងៃឡើងស័ក គម្រប់ជាសង្ក្រាន្ត៣ថ្ងៃ ដោយបរិបូរណ៍ និងចូលឆ្នាំច សំរឹទ្ធិស័ក តរៀងទៅ។

ដើម្បីបង្កភាពសប្បាយរីករាយ រក្សាប្រពៃណីទំនៀមទម្លាប់របស់ជាតិឲ្យបានគង់វង្ស និងប្រកប ដោយភាពរុងរឿង និងរក្សាបានសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនោះ រដ្ឋបាលខេត្តកំពង់ធំ សូមធ្វើការណែនាំដូចខាងក្រោម៖

**១. រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលឃុំសង្កាត់៖**

- ត្រូវរៀបចំតាំងព្រះបរមឆាយាល័ក្ខណ៍ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា **ព្រះករុណា«ព្រះបរមរតនកោដ្ឋ»** និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដោយមានតុបតែងលម្អ កំណាត់បូ បំភ្លឺភ្លើងពណ៌ និងចងបដាពាក្យស្លោក ទង់ជាតិ ទង់ក្ដែប ទង់រំយោល តាមការិយាល័យ អង្គភាព សាលារៀន វត្តអារាម។
- ណែនាំដល់ម្ចាស់រោងចក្រ សហគ្រាស សាលារៀនឯកជន មណ្ឌលកម្សាន្ត រមនីយដ្ឋាននានា និងគ្រប់គេហដ្ឋានប្រជាពលរដ្ឋ ឲ្យចងទង់ជាតិ ដុតគោម អុជប្រទីបផ្កាលាបំភ្លឺ ឲ្យបានព្រោងព្រាត ដើម្បីអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិយើង។
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីការពាររក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ជួយសម្រួលចរាចរណ៍គ្រប់ទីកន្លែង និងបង្ករលក្ខណៈល្អប្រសើរតាមមណ្ឌលកម្សាន្ត តាមរមណីយដ្ឋាន

នានា ជូនប្រជាពលរដ្ឋ ភ្ញៀវជាតិ-អន្តរជាតិ ចូលរួមកម្សាន្តសប្បាយ។

- ចាត់តាំងឲ្យមានការលេងល្បែងប្រជាប្រិយរបស់ជាតិ ដូចជា ចោលឈូង បោះអង្គញ់ ទាញព្រ័ត្រ ទាត់សី លាក់កន្សែង រាំកម្សាន្ត តាមមណ្ឌលកម្សាន្ត តាមរមណីយដ្ឋាននានា ឬទីណាដែលសមគួរ ហើយជៀសវាង និងទប់ស្កាត់ឲ្យបាននូវល្បែងណាដែល ប្រាស់ចាកនឹងច្បាប់ ហើយខុសនឹងប្រពៃណីជាតិ ដូចជា ល្បែងស៊ីសង ល្បែងភ្នាល់ ល្បែងជះទឹក លាបម្សៅ ប៉ាតម្សៅ និងគ្រឿងផ្ទុះផ្សេងៗ ។ល។
- ត្រូវយកចិត្តទុកដាក់បំផុសស្មារតីប្រុងប្រយ័ត្នក្នុងការដុតទៀន ធូប ភ្លើងចង្ក្រាន ចរន្តអគ្គិសនី និងគ្រឿងឆេះផ្សេងៗ ដែលនាំឲ្យមានគ្រោះអគ្គិភ័យ។
- ចាត់តាំងឲ្យមានពិធីបុណ្យសាសនាតាមវត្តអារាម និងពិធីបង្សុកូលឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធបងប្អូនជនរួមជាតិ ដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ នៅតាមបូជនីយដ្ឋាន ស្តូប វត្តអារាម ឬទីកន្លែងណាដែលបានតម្កល់អដ្ឋិធាតុ។

**២. ស្នងការនគរបាលខេត្ត បញ្ជាការដ្ឋានអាវុធហត្ថខេត្ត និងតំបន់ប្រតិបត្តិការសឹករងខេត្ត៖**

- ត្រូវមានផែនការណែនាំជាក់លាក់ដល់អង្គភាពក្រោមឱវាទរបស់ខ្លួន និងសហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដើម្បីការពារ រក្សាសន្តិសុខ របៀបរៀបរយសាធារណៈសង្គម ធានាបានសុវត្ថិភាពមុន-ក្រោយ និងក្នុងពេលប្រារព្ធពិធីបុណ្យចូលឆ្នាំ នៅក្នុងភូមិសាស្ត្រខេត្ត នៅតាមវត្តអារាម មណ្ឌលកម្សាន្ត រមណីយដ្ឋាននានា និងយកចិត្តទុកដាក់សម្រួលចរាចរណ៍នៅគ្រប់ទីកន្លែង ដើម្បីបង្កការសប្បាយរីករាយជូនប្រជាពលរដ្ឋចូលកំសាន្ត។
- ត្រូវសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីមានវិធានការទប់ស្កាត់ និងលុបបំបាត់នូវសកម្មភាពណាដែលល្មើសច្បាប់ ប្រាស់ចាកនឹងប្រពៃណីទំនៀមទម្លាប់ជាតិ។

**៣.មន្ទីរធម្មការ និងសាសនា ៖**

- ត្រូវសហការជាមួយព្រះគ្រូចៅអធិការ គណៈកម្មការអាចារ្យវត្ត និងណែនាំដល់គ្រប់វត្តអារាមទាំងអស់ សម្អាត និងតុបតែងលម្អទង់ជាតិ ទង់សាសនា ទង់ក្អែប ទង់រំយោល បដាពាក្យស្លោកឲ្យបានសមរម្យ និងសហការជាមួយរដ្ឋបាលក្រុងស្រុក និងឃុំសង្កាត់ រៀបចំពិធីបុណ្យសាសនា តាមវត្តអារាមស្របតាមប្រពៃណីសាសនា ប្រពៃណីជាតិ ដូចជា ពិធីពូនភ្នំខ្សាច់ សម្អាតបរិស្ថានក្នុងវត្ត សម្អាតព្រះពុទ្ធរូប ព្រះបដិមា ពិធីស្រោចទឹកសីលវត្ត សីលវតី មាតា បិតា ចាស់ព្រឹទ្ធាចារ្យ ជាដើម។
- ចាត់តាំងពិធីបង្សុកូលឧទ្ទិសកុសល ជូនដល់វិញ្ញាណក្ខន្ធរបស់បងប្អូនជនរួមជាតិ ដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ នៅតាមបូជនីយដ្ឋាន ស្តូប វត្តអារាម និងតាមទីកន្លែងតម្កល់អដ្ឋិធាតុ ។

**៤. មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ៖**

- ត្រូវសហការជាមួយរដ្ឋបាលក្រុងស្រុក និងឃុំសង្កាត់ ចាត់តាំងសម្តែងសិល្បៈ និងប្រគំតន្ត្រីបុរាណ-សម័យ ជូនប្រជាពលរដ្ឋទស្សនាកម្សាន្តតាមទីសាធារណៈ និងចាត់តាំងលេងល្បែងប្រជាប្រិយរបស់ជាតិ មានចោលឈូង បោះអង្គញ់ ទាញព្រ័ត្រ ទាត់សី លាក់កន្សែង រាំកម្សាន្ត ។ល។ នៅតាមវត្តអារាម មណ្ឌលកម្សាន្ត រមណីយដ្ឋាននានា ឬទីតាំងសមស្របណាមួយដែលបងប្អូនប្រជាពលរដ្ឋយើងតែងនិយមចូលចិត្ត អញ្ជើញទៅកម្សាន្ត។

**៥. មន្ទីរព័ត៌មាន៖**

- ត្រូវចាត់តាំងមន្ត្រីចុះយកព័ត៌មាន ថតផ្តិតយករូបភាពរាល់សកម្មភាព និងទិដ្ឋភាព ជាក់ស្តែងនាថ្ងៃបុណ្យចូលឆ្នាំថ្មីនេះ ដែលរួមមាន សកម្មភាពនៃពិធីសាសនាតាម វត្តអារាម និងសកម្មភាពលេងល្បែងប្រជាប្រិយ ហើយធ្វើការផ្សព្វផ្សាយឲ្យបានទូលំទូលាយតាមទូរទស្សន៍ និងតាមបណ្តាញ

ផ្សេងៗ។

**៦. ប្រធានមន្ទីរ អង្គភាព អភិបាលក្រុងស្រុក និងអង្គការសង្គមស៊ីវិលនានា៖**

- ត្រូវបំផុស និងអំពាវនាវដល់បណ្ដាសប្បុរសជន ជួយឧបត្ថម្ភអំណោយជាសម្ភារ ថវិកា ចុះសួរសុខទុក្ខអ្នកជំងឺ ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យនានា ជនពិការ កុមារកំព្រានៅតាមមណ្ឌលនានា បងប្អូនប្រជាពលរដ្ឋក្រីក្រដែលខ្វះខាត និងចាស់ជរាគ្មានទីពឹង ដើម្បីជាការលើកទឹកចិត្ត និងបង្កើនស្មារតីជួយគ្នាទៅវិញទៅមក ក្នុងគ្រាមានទុក្ខលំបាក ក៏ដូចជាក្នុងឱកាសសប្បាយរីករាយ។

រដ្ឋបាលខេត្តកំពង់ធំ មានសង្ឃឹមយ៉ាងមុតមាំលើស្មារតីទទួលខុសត្រូវខ្ពស់របស់លោក លោកស្រី ប្រធានមន្ទីរ អង្គភាព អភិបាលក្រុងស្រុក មេឃុំចៅសង្កាត់ ប្រជាពលរដ្ឋ និង លោក លោកស្រី ដែលមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ ក្នុងការចាត់តាំងអនុវត្តសេចក្ដីណែនាំនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ...ពុធ ១១រោច.... ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

ធ្វើនៅកំពង់ធំ ថ្ងៃទី......១១........ ខែមេសា ឆ្នាំ២០១៨

**អភិបាល**

សុខ~លុ

**__កន្លែងទទួល ÷__**

- ក្រសួងមហាផ្ទៃ
- គណៈកម្មាធិការរៀបចំបុណ្យជាតិ-អន្តរជាតិ
- ក្រុមប្រឹក្សាខេត្ត
  «ដើម្បីគោរពជូនជ្រាប»
- គ្រប់មន្ទីរ អង្គភាព រដ្ឋបាលក្រុង-ស្រុក
  «ដើម្បីសហការអនុវត្ត»
- មន្ទីរព័ត៌មាន
  «ដើម្បីផ្សព្វផ្សាយ»
- ឯកសារ-កាលប្បវត្តិ